# តំណក់នៃសេចក្ដីជំនឿ

*យ៉ាកុបមានបញ្ហាមួយ—គាត់តែងតែងងុយដេក !*

ដោយ ប៉ូលីយ៉ាណា ម៉ាតូស វេគីអូ
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅប្រទេសប្រេស៊ីល ។*

« យ៉ាកុប តើប្អូនដឹងចម្លើយទេ ? » លោកស្រី ឡេលីសសួរ ។

យ៉ាកុបបានបើកភ្នែករបស់គាត់ ហើយងើបមុខឡើង ។ មិត្តរួមថ្នាក់របស់គាត់ទាំងអស់បានសម្លឹងមើលគាត់ ។ គ្រូបង្រៀនរបស់គាត់ក៏បានសម្លឹងមើលគាត់ផងដែរ ។ គាត់មានអារម្មណ៍ថាថ្ពាល់របស់គាត់ឡើងក្ដៅ ។ គាត់ដេកលក់នៅក្នុងថ្នាក់រៀនទៀតហើយ !

គាត់បានឆ្លើយថា « សុំទោសលោកស្រី ឡេលីស » ។ « តើអ្នកគ្រូអាចនិយាយសំណួរនេះម្ដងទៀតបានទេ ? »

« បានកូន ។ ប៉ុន្តែសូមឈប់ដេកនៅក្នុងថ្នាក់រៀន » ។

គាត់បានអង្គុយចុះនៅលើកៅអីរបស់គាត់ ។ « បាទអ្នកគ្រូ » ។

យ៉ាកុបបានមកសាលាថ្មីរបស់គាត់កាលពីពីរបីសប្ដាហ៍មុន ។ គាត់ចូលចិត្តរៀន ហើយមិត្តរួមថ្នាក់របស់គាត់គឺល្អៗណាស់ ។ ប៉ុន្តែមានបញ្ហាមួយ—គាត់តែងតែងងុយដេក ! សាលាថ្មីរបស់គាត់នៅឆ្ងាយណាស់ ដូច្នេះគាត់ត្រូវភ្ញាក់តាំងពីព្រលឹមស្រាងៗដើម្បីទៅដល់ទីនោះឲ្យទាន់ពេល ។

ដំបូងវាងាយស្រួលនៅក្នុងយកចិត្តទុកដាក់នៅក្នុងថ្នាក់រៀន ។ ប៉ុន្តែវាកាន់តែពិបាកឡើងៗ ។ ពេលខ្លះ យ៉ាកុបនឿយហត់ខ្លាំងណាស់ ហើយគាត់បានដេកលក់ ។

នៅថ្ងៃបន្ទាប់ នាយកសាលាបានសុំឲ្យយ៉ាកុប និងឪពុកម្ដាយរបស់យ៉ាកុបជួបជាមួយគាត់ ។ គាត់បានញញឹម ហើយស្វាគមន៍ពួកគេចូលទៅក្នុងការិយាល័យរបស់គាត់ ។

គាត់បាននិយាយថា « ខ្ញុំរីករាយណាស់ដែលអ្នកនៅទីនេះ » ។ « យ៉ាកុបជាសិស្សល្អណាស់ ។ ប៉ុន្តែគ្រូរបស់គាត់និយាយថាគាត់មិនចាប់អារម្មណ៍នឹងថ្នាក់រៀនរបស់គាត់ទេ ។ ពេលខ្លះ គាត់មិនយកចិត្តទុកដាក់ ហើយគាត់ហាក់ដូចជានឿយហត់ខ្លាំងណាស់ ។ « តើគាត់កើតអីទេ ? »

ម្ដាយរបស់គាត់បានងក់ក្បាល ។ « យ៉ាកុបព្យាយាមខ្លាំងណាស់ដើម្បីមកសាលារៀននៅទីនេះ ប៉ុន្តែសាលានៅឆ្ងាយពីផ្ទះយើង ។ គាត់ត្រូវភ្ញាក់តាំងពីព្រលឹមស្រាងៗជារៀងរាល់ថ្ងៃ ។ ដូច្នេះគាត់ងងុយដេកនៅក្នុងថ្នាក់ពេលព្រឹករបស់គាត់ » ។

នាយកសាលានិយាយថា « អូ៎!ប៉ុណ្ណឹងទេឬ ? » ។ « អ្នកគួរសាកល្បងប្រើដំណក់កាហ្វេ ! សូមដាក់កាហ្វេរសជាតិខ្លាំងពីរបីដំណក់ចូលទៅក្នុងភេសជ្ជៈរបស់យ៉ាកុបជារៀងរាល់ព្រឹកទៅ ។ នោះនឹងធ្វើឲ្យគាត់លែងងងុយដេកហើយ » ។

យ៉ាកុបមុខស្រពោន ។ « ប៉ុន្តែគ្រួសាររបស់យើងអត់ផឹកកាហ្វេទេលោកស្រី » ។

នាយកសាលាមើលទៅដូចជាច្របូកច្របល់ ។ « វានឹងពិបាកក្នុងការរៀន ប្រសិនបើប្អូនចេះតែដេកលក់អីចឹង ។ យ៉ាងហោចណាស់ប្អូនគួរតែគិតអំពីរឿងនេះ » ។





នៅពេលដែលពួកគេចាកចេញពីការិយាល័យនាយកសាលា យ៉ាកុបបានមានគំនិតច្របូកច្របល់ ។ គាត់ចង់ធ្វើឲ្យបានប្រសើរឡើងនៅសាលារៀន ប៉ុន្តែគាត់ក៏ចង់ធ្វើតាមបទបញ្ញត្តិផងដែរ ។

យប់នោះគ្រួសាររបស់គាត់បានអានអំពីពាក្យសម្ដីនៃប្រាជ្ញាវាងវៃនៅក្នុងព្រះគម្ពីរ ។

នៅពេលដល់វេនរបស់យ៉ាកុប គាត់បានអានថា « ហើយពួកបរិសុទ្ធទាំងអស់ដែលនឹកចាំកាន់តាម ហើយប្រព្រឹត្តតាមពាក្យសម្ដីទាំងនេះ . . . នឹងរកឃើញប្រាជ្ញា និងផលថ្លៃវិសេសនៃចំណេះវិជ្ជា ។ ហើយនឹងរត់ទៅតែដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ » ។*

បន្ទាប់មកគាត់មានគំនិតមួយ !

គាត់បានក្រោកចេញពីកៅអីរបស់គាត់ ។ « ជំនួសឲ្យដំណក់កាហ្វេ ខ្ញុំនឹងប្រើតំណក់នៃសេចក្ដីជំនឿវិញ ! »

ប៉ារបស់គាត់បានសួរថា « តើកូនចង់មានន័យថាម៉េច ? »

យ៉ាកុបញញឹម ។ « រាល់ពេលព្រឹកមុនអាហារពេលព្រឹកយើងអាចនិយាយការអធិស្ឋានមួយ ហើយទូលសុំឲ្យព្រះវរបិតាសួគ៌ប្រទានពរដល់កូន ដើម្បីកុំឲ្យកូនមានអារម្មណ៍ងងុយគេង ។ ការអធិស្ឋានរបស់យើងនឹងប្រៀបដូចជាតំណក់នៃសេចក្ដីជំនឿ ! »

ម៉ាក់ និងប៉ាក៏ញញឹមដែរ ។ ប៉ាបានឆ្លើយថា « ស្ដាប់ទៅដូចជាគំនិតល្អណាស់ ! »

នៅព្រឹកស្អែកឡើង គ្រួសាររបស់ពួកគេបានលុតជង្គង់ ហើយបាននិយាយនៅក្នុងការអធិស្ឋានសុំឲ្យយ៉ាកុបនឹងមានថាមពលដើម្បីកុំឲ្យងងុយគេង ។ ពួកគេបានធ្វើរឿងដូចគ្នានៅថ្ងៃស្អែក ។ ហើយថ្ងៃបន្ទាប់ទៀតៗផងដែរ ។ ជារៀងរាល់យប់ យ៉ាកុបបានព្យាយាមចូលគេងពីព្រលប់ ។ ហើយរៀងរាល់ព្រឹកគ្រួសាររបស់យ៉ាកុបមានជំនឿថាព្រះវរបិតាសួគ៌នឹងជួយដល់គាត់ ។

យូរៗទៅ ដំណក់នៃសេចក្ដីជំនឿរបស់ពួកគេបានមានដំណើរការ ។ យ៉ាកុបអាចយកចិត្តទុកដាក់ពេញមួយថ្ងៃបាន ! ព្រះបានឆ្លើយតបការអធិស្ឋានរបស់ពួកគេ ។ ហើយយ៉ាកុបបានដឹងថាគាត់មានមោទនភាពចំពោះខ្លួនឯង ដែលបានធ្វើតាមពាក្យសម្ដីនៃប្រាជ្ញាវាងវៃ ។

« យ៉ាកុប ត្រៀមខ្លួនសម្រាប់ថ្នាក់រៀនហើយឬនៅ ? » លោកស្រី ឡេលីសបានសួរនៅពេលព្រឹកមួយនៅពេលដែលគាត់ដើរចូលទៅក្នុងថ្នាក់រៀន ។

យ៉ាកុបបានងក់ក្បាលដោយញញឹមយ៉ាងធំនៅលើមុខរបស់គាត់ ។ គាត់មានដំណក់នៃសេចក្ដីជំនឿរបស់គាត់មុនទៅសាលារៀន ។ គាត់ត្រៀមខ្លួនជាស្រេចសម្រាប់អ្វីទាំងអស់ ! ●

### តើពាក្យសម្ដីនៃប្រាជ្ញាវាងវៃជាអ្វី ?

ពាក្យសម្ដីនៃប្រាជ្ញាវាងវៃគឺជាបញ្ញត្តិមួយដែលព្រះបានប្រទានមក ដើម្បីប្រទានពរដល់បុត្រាបុត្រីរបស់ទ្រង់ ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៩ ) ។ បញ្ញត្តិនេះប្រាប់យើងអំពីអាហារអ្វីដែលល្អសម្រាប់បរិភោគ និងអាហារមួយចំនួនដើម្បីចៀសវាង ។ នៅពេលដែលយើងធ្វើតាមបញ្ញត្តិនេះ យើងទទួលបានពរឲ្យមានសុខភាពល្អ កម្លាំង និងប្រាជ្ញា !

*គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៩:១៨–២០